ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## និរាករណ៍អនុក្រឹត្យ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យ ស្តីពីការធ្វើអនុបយោគផ្ទៃដីក្នុងតំបន់ការពារធម្មជាតិ ក្នុងភូមិសាស្ត្រ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-យោងលិខិតលេខ ១៣៦៥ សជណ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**មាត្រា ១.-**

ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **វិមានសិលា អិលធីឌី (VIMEAN SEILA LTD)** លើផ្ទៃដីទំហំ ៩៨៧ **(ប្រាំបួនរយប៉ែតសិបប្រាំពីរ) ហិកតា** លើកោះថ្មី នៃឧទ្យានជាតិព្រះសីហនុ "រាម" ភូមិសាស្ត្រខេត្តព្រះសីហនុ ដូចខាងក្រោម៖

- អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៩៨៧ (ប្រាំបួនរយប៉ែតសិបប្រាំពីរ) ហិកតា ស្ថិតក្នុងកោះថ្មី នៃតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ខេត្តព្រះសីហនុ។

ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **ស៊ាន់ វឌ្ឍនៈ ខូ អិលធីឌី (SUON VATANAK CO.,LTD)** លើផ្ទៃដីទំហំ ៥៨៥ (ប្រាំរយប៉ែតសិបប្រាំ) ហិកតា ក្នុងតំបន់ទ្រនាប់សត្វឆ្លងកាត់រវាងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" និងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចខាងក្រោម៖

- អនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- អនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៥៨៥ (ប្រាំរយប៉ែតសិបប្រាំ) ហិកតា ស្ថិតក្នុងតំបន់ទ្រនាប់សត្វឆ្លងកាត់ រវាងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ "គីរីរម្យ" និងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ។

ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យ ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **ច័ន្ទ រតន៍ គ្រុប លើផ្ទៃដីទំហំ ៦៣ (ហុកសិបបី) ហិកតា** ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ក្នុងភូមិសាស្ត្រឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ដូចខាងក្រោម៖

- អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។ -

**មាត្រា ២.-**

ផ្ទៃដីដែលគ្របដណ្តប់ដោយបណ្តាអនុក្រឹត្យ ដែលត្រូវបាននិរាករណ៍ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវដាក់បញ្ចូលជាដីឧទ្យានជាតិព្រះសីហនុ **"រាម"** ឧទ្យានជាតិព្រះសុរាម្រិត-កុសុមៈ **"គីរីរម្យ"** និងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ